



# បើសិនជារូបអ្នក ឬគ្រួសារអ្នក...

- រស់នៅជាមួយសាច់ញាតិឬមិត្តភក្តិដោយសារអ្នកមិនអាច រក ឬមានប្រាក់អាចទិញផ្ទះដោយខ្លួនឯងបាន:
- រស់នៅតាមដងផ្លូវ;
- រស់នៅតាមអាគារដែលគេបោះបង់ចោល យានសណ្តោង ឬតាមអាគារដែលគ្មានគ្រឿងជួយសម្រប សម្រួលគ្រប់គ្រាន់ លក្ខខ័ណ្ឌទាំងនោះអាចមានរួមទាំងកង្វះអគ្គិសនី ប្រព័ន្ធបង្ហូរទឹក ឬទឹកហូរ: ឬ
- រស់នៅតាមជំរកណាមួយ តាមផ្ទះសំណាក់ រថយន្ត ឬតាមកន្លែងបោះជំរុំ ។

ច្បាប់ជំនួយអប់រំសំរាប់ជនគ្មានផ្ទះសម្បែង McKinney-Vento (McKinney-Vento Homeless Education Assistance Act) ផ្តល់ការពារមួយចំនួន ។

រូបអ្នក ឬកូនរបស់អ្នកមានសិទ្ធិក្នុងការ:

- ទៅសាលារៀន ទោះជាអ្នករស់នៅទីណាក៏ដោយឬទោះជាបានរស់នៅទីនោះយូរក៏ដោយ ។
- បន្តទៅសាលារៀនដែលអ្នក/កូនអ្នកធ្លាប់បានទៅរៀន មុនពេលអ្នកក្លាយទៅជាជនគ្មានផ្ទះសម្បែង ឬសាលាបានចូលរៀនចុងក្រោយ បើនេះជាចំណូលចិត្តរបស់អ្នក ហើយបើអាចធ្វើបាន ។
- ទទួលការដឹកនាំទៅកាន់សាលាដែលអ្នក/កូនអ្នកធ្លាប់ បានទៅរៀនមុនពេលអ្នកក្លាយទៅជាជនគ្មានផ្ទះសម្បែង ឬសាលាបានចូលរៀនចុងក្រោយ បើសិនជាអ្នក មាតា ឬបិតាម្នាក់ ឬអ្នកអាណាព្យាបាលសុំមកសាលាសំរាប់ការដឹកនាំនេះ ។
- ទៅសាលារៀន និងចូលរៀនក្នុងកម្មវិធីសាលានានាជាមួយសិស្សដែលមិនមែនជាអ្នកគ្មានផ្ទះសម្បែង ។
- ចុះឈ្មោះក្នុងសាលាដោយមិនចាំបាច់ផ្តល់អាស័យដ្ឋាន អចិន្ត្រៃយ៍ ។
- ចុះឈ្មោះក្នុងសាលា និងចូលរៀនក្នុងថ្នាក់ខណៈដែលសាលារៀបចំសំរាប់ការអប់រំដែលត្រូវការ និងសំណុំ បញ្ជីរឿងពេទ្យ ។
- ចុះឈ្មោះ និងចូលរៀនថ្នាក់ក្នុងសាលាដែលជាជម្រើសរបស់អ្នក ទោះបីជាខណៈដែលសាលា និងរូបអ្នកដោះស្រាយភាពផ្ទុយគ្នាអំពីតើសាលាមួយណាដែលរូបអ្នក/កូនរបស់អ្នកនឹងទៅរៀន ។
- ទទួលកម្មវិធីពិសេសដូចគ្នានិងសេវានានាដែលបានផ្តល់ទៅឲ្យសិស្សដទៃៗទៀត ។
- ទទួលការដឹកនាំតាមយានជំនិះទៅសាលា និងទៅកម្មវិធីសាលានានា ។
- ស្នើសុំទៅអ្នកទំនាក់ទំនងរវាងមណ្ឌលសិក្សាធិការ និងផ្នែកជនគ្មានផ្ទះសម្បែងដើម្បីជួយក្នុងការទទួលចំណីអាហារ សំលៀកបំពាក់ និងគ្រឿងផ្គត់ផ្គង់សាលា ។

រូបអ្នក ឬកូនរបស់អ្នកអាចមានលទ្ធភាពទទួល:

- អាហារសាលាដោយឥតគិតថ្លៃ
- សៀវភៅនិងគ្រឿងផ្គត់ផ្គង់ពីសាលាដោយឥតគិតថ្លៃ
- ប័ណ្ណជិះប៊ុសឥតគិតថ្លៃ (កាស)
- ការដឹកនាំតាមយានជំនិះទៅកាន់កម្មវិធីសាលា
- កម្រៃផ្សេងៗដទៃទៀត

សូមទាក់ទងមកអ្នកទំនាក់ទំនងរវាងមណ្ឌលសិក្សា និងផ្នែកជនគ្មានផ្ទះសម្បែងតាម:

អ្នកក៏អាចទាក់ទងមកអ្នកសម្របសម្រួលរដ្ឋផ្នែកជនគ្មានផ្ទះសម្បែងតាម:

# If You or your family...

- live with relatives or friends because you can't find or afford housing on your own;
- live on the street;
- live in an abandoned building, trailer or a building with inadequate accommodations (these conditions may include lack of electricity, plumbing or running water); or
- live in a shelter, motel, vehicle or campground.

## The McKinney-Vento Homeless Education Assistance Act provides certain protections.

**You or your children have the right to:**

- Go to school, no matter where you live or how long you have lived there.
- Continue to go to the school you /your children were attending before becoming homeless, or the school last attended, if that is your preference and it is feasible.
- Receive transportation to the school you /your children attended before becoming homeless, or the school last attended, if you, a parent or guardian asks the school for this transportation.
- Go to school and attend school programs with students who are not homeless.
- Enroll in school without giving a permanent address.
- Enroll in school and attend classes while the school arranges for needed educational and medical records.
- Enroll and attend classes in the school of your choice even while the school and you resolve differences over which school you /your children will attend.
- Receive the same special programs and services given to all other students.
- Receive transportation to school and to school programs.
- Ask the school district's homeless liaison for help in getting food, clothing, and school supplies.

**You or your children may be able to receive:**

- Free school lunch
- Free school books and supplies
- Free bus tickets (tokens)
- Transportation to school programs
- Other benefits

Please contact the **school district's homeless liaison** at:

You may also contact the **state homeless coordinator** at:

A QUALITY EDUCATION FOR EVERY CHILD
New Wisconsin Promise
WISCONSIN DEPARTMENT OF PUBLIC INSTRUCTION

SUPERINTENDENT OF PUBLIC INSTRUCTION WASHINGTON

Cambodian